**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**កំពង់ផែស្វយ័តក្រុងព្រះសីហនុ**

លេខៈ ០១៦ សជណ/កសស/បេ.ធម

ថ្ងៃ ចន្ទ ១៤ កើត ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៧

ខេត្តព្រះសីហនុ ថ្ងៃទី ២២ ខែមេសា ឆ្នាំ២០២៤

# សេចក្តីជូនដំណឹង (លើកទី២)

# ស្តីពី

# ការជ្រើសរើសបេក្ខជនឈរឈ្មោះជាអភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជន សម្រាប់ជាសមាជិកក្រុមប្រឹក្សាភិបាល កំពង់ផែស្វយ័តក្រុងព្រះសីហនុ អាណត្តិទី៩

**កំពង់ផែស្វយ័តក្រុងព្រះសីហនុ (កសស)** ជាសហគ្រាសសាធារណៈ បោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈនៅលើផ្សារមូលបត្រកម្ពុជា នាថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៧ ។ **កសស** ជាកំពង់ផែអន្តរជាតិសមុទ្រទឹកជ្រៅ ដែលដើរតួនាទីជាប្រតិបត្តិករផែ និងអាជ្ញាធរផែ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

យោងតាមលក្ខន្តិកៈរបស់ **កសស** ក្រុមប្រឹក្សាភិបាលអាណត្តិទី៩ ត្រូវមានសមាសភាពចំនួន ០៧(ប្រាំពីរ)រូប ដែលក្នុងនោះ ០១(មួយ)រូប ជាអភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជន ។

អាស្រ័យហេតុនេះ **កសស** មានកិត្តិយសសូមជម្រាបជូនដំណឹងដល់សាធារណជនទាំងអស់ឲ្យបានជ្រាបថា ៖ **កសស** នឹងចាប់ផ្តើមទទួលពាក្យរបស់បេក្ខជនដែលមានបំណងឈរឈ្មោះជាអភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជន សម្រាប់ដាក់ជូនមហាសន្និបាតភាគហ៊ុនិកលើកទី៧ ធ្វើការបោះឆ្នោតជ្រើសតាំងជាសមាជិកក្រុមប្រឹក្សាភិបាល សម្រាប់អាណត្តិទី៩ ដែលមានរយៈពេល ០៣(បី)ឆ្នាំ ។

## ១. លក្ខខណ្ឌ និងគុណវុឌ្ឍិ នៃការជ្រើសរើស

បេក្ខជនដែលមានបំណងដាក់ពាក្យឈរឈ្មោះ ជាអភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជនត្រូវបំពេញលក្ខខណ្ឌ និងមានគុណវុឌ្ឍិ ដូចខាងក្រោម៖

- ត្រូវកាន់កាប់ ឬតំណាងអោយអ្នកកាន់កាប់ មូលបត្រកម្មសិទ្ធិដែលមានសិទ្ធិបោះឆ្នោតរបស់ កសស ចំនួន ១ ភាគរយ (២១៤,៤២៩ មូលបត្រ) ឡើងទៅ នៃមូលបត្រកម្មសិទ្ធិមានសិទ្ធិបោះឆ្នោតប្រភេទ "គ"
- ត្រូវមានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ ឬសញ្ញាបត្រសមមូល ខាងផ្នែកគ្រប់គ្រងការងារកំពង់ផែ ផ្នែកដឹកជញ្ជូន ឬផ្នែកភស្តុភារកម្ម
- ត្រូវមានអាយុចាប់ពី ៣៥ (សាមសិបប្រាំ) ឆ្នាំ ឡើងទៅ ( គិតត្រឹមថ្ងៃដាក់ពាក្យ )
- ត្រូវមានបទពិសោធន៍ការងារយ៉ាងតិច ០៣ (បី) ឆ្នាំ ផ្នែកគ្រប់គ្រងកំពង់ផែ ផ្នែកដឹកជញ្ជូន ឬផ្នែកភស្តុភារកម្ម ( គិតត្រឹមថ្ងៃដាក់ពាក្យ )



តិវិថី សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ
Tarak Vithei Samdech Akka Moha Sena Padei Techo HUN SEN
Sangkat N° 3, Preah Sihanouk City, Preah Sihanouk Province
Office : 034 933 416; 034 933 511 Pilot : 034 933 507; Fax: 034 933 693
E-mail: pasinfo@pas.gov.kh; spsez@pas.gov.kh
Website: www.pas.gov.kh

- ចំពោះបេក្ខជនដែលមានសញ្ជាតិបរទេស ត្រូវមានបទពិសោធន៍ការងារក្នុងប្រទេសកម្ពុជាយ៉ាងតិចរយៈពេល ០៦ (ប្រាំមួយ) ខែ ( គិតត្រឹមថ្ងៃដាក់ពាក្យ )
- មិនធ្លាប់ត្រូវបានដកហូតអាជ្ញាបណ្ណ ឬការអនុញ្ញាត ឬត្រូវបានហាមឃាត់បំពេញតួនាទីជាអភិបាល ឬអ្នកគ្រប់គ្រងក្រុមហ៊ុន ក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំចុងក្រោយ
- មិនធ្លាប់ត្រូវបានប្រកាសក្ស័យធនដោយតុលាការ ក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំចុងក្រោយ
- ត្រូវមានលិខិតថ្កោលទោស ដែលបញ្ជាក់ថាមិនធ្លាប់បានផ្តន្ទាទោសក្នុងបទមជ្ឈិម ឬបទឧក្រិដ្ឋ (ត្រូវប្រគល់លិខិតបញ្ជាក់ក្រោយពីត្រូវបានបោះឆ្នោតជ្រើសតាំង)
- មាននីត្យានុកូលភាព ទេពកោសល្យ សមត្ថភាព និងសុចរិតភាព
- មានការប្តេជ្ញាចិត្តខ្ពស់ដើម្បីផលប្រយោជន៍របស់ **កសស** និងភាគហ៊ុនិក
- មានពេលវេលា ថាមពល និងការគាំទ្រ ដើម្បីបំពេញគ្រប់ភារកិច្ច រួមមានការជួបប្រជុំ និងការចូលរួមសន្និសីទផ្សេងៗ
- មានលទ្ធភាពធ្វើការជាក្រុមប្រកបដោយប្រសិទ្ធភាព
- មានលទ្ធភាពធ្វើការផ្តល់ប្រសិទ្ធភាពឆ្ពោះទៅរកគោលដៅរួមរបស់ សហគ្រាស និងភាគហ៊ុនិក
- យល់អំពីតួនាទីរបស់ខ្លួនជាអភិបាលក្នុងធុរកិច្ច
- បង្ហាញភាពជាអ្នកដឹកនាំ
- មានលទ្ធភាពដើរតួនាទីយ៉ាងសកម្មនៅពេលដែល កសស ជួបប្រទះស្ថានភាពវឹកវរ ។

## ២. សំណុំលិខិតក្នុងការដាក់ពាក្យឈរឈ្មោះ

| | |
|---|---|
| • សំណើសុំឈរឈ្មោះជាបេក្ខជន | ចំនួន ០១ ច្បាប់ |
| • ជីវប្រវត្តិរូបសង្ខេប (CV) មានបិទរូបថត (៤x៦) | ចំនួន ០១ ច្បាប់ |
| • អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែន (ជនបរទេស) | ចំនួន ០១ ច្បាប់ |
| • សេចក្តីចម្លងសញ្ញាបត្រដែលមានការបញ្ជាក់ត្រឹមត្រូវ | ចំនួន ០១ ច្បាប់ |
| • លិខិតបញ្ជាក់ការងារ (Letter of Recommendation) | ចំនួន ០១ ច្បាប់ |

## ៣. ការទទួលខុសត្រូវ

- ជាសមាជិកក្រុមប្រឹក្សាភិបាល
- ជាសមាជិកគណៈកម្មាធិការ តាមការសម្រេចរបស់ក្រុមប្រឹក្សាភិបាល
- ចូលរួមនៅក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាល និងមហាសន្និបាតភាគហ៊ុនិក
- ចូលរួមអនុម័តគោលនយោបាយ និងនីតិវិធីអនុវត្តសម្រាប់ **កសស**
- ចូលរួមចំណែក និងអនុវត្តផែនការយុទ្ធសាស្ត្រ និងតាមដានការអនុវត្តគោលនយោបាយ
- ចូលរួមក្នុងការធានាការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុទ្ធផ្សេងៗ
- ចូលរួមក្នុងការធានាសោធនភាពហិរញ្ញវត្ថុរបស់ **កសស** តាមរយៈការគ្រប់គ្រង និងត្រួតពិនិត្យហិរញ្ញវត្ថុ
- ផ្តល់នូវភាពជាអ្នកដឹកនាំ ការគាំទ្រ និងការលើកទឹកចិត្តដល់និយោជិត
- ចូលរួមក្នុងការធានាថាក្រុមប្រឹក្សាភិបាលមានប្រសិទ្ធភាពក្នុងការដឹកនាំ **កសស**
- ចូលរួមក្នុងការសម្រេចគោលដៅ របស់ **កសស**
- ផ្តល់នូវទស្សនៈវិស័យស្តីពីប្រសិទ្ធិភាព និងគណនេយ្យភាពចំពោះភាគហ៊ុនិក
- ការទទួលខុសត្រូវផ្សេងទៀត តាមការចាំបាច់ ។



តិរវិថី សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ
Tarak Vithei Samdech Akka Moha Sena Padei Techo HUN SEN
Sangkat Nº 3, Preah Sihanouk City, Preah Sihanouk Province
Office : 034 933 416; 034 933 511 Pilot : 034 933 507; Fax: 034 933 693
E-mail: pasinfo@pas.gov.kh; spsez@pas.gov.kh
Website: www.pas.gov.kh

## ៤. អត្ថប្រយោជន៍ដែលទទួលបាន

- ប្រាក់បៀវត្សប្រចាំខែ
- ការឧបត្ថម្ភជូននូវមធ្យោបាយធ្វើដំណើរ និងប្រេងឥន្ធនៈប្រចាំខែ
- ប្រាក់ឧបត្ថម្ភថ្លៃអាហារប្រចាំខែ
- ប្រាក់ថ្លៃងសរសើរប្រចាំឆ្នាំ
- ឧបត្ថម្ភសំលៀកបំពាក់ប្រចាំឆ្នាំ
- ប្រាក់ឧបត្ថម្ភផ្សេងៗទៀត នាឱកាសបុណ្យចូលឆ្នាំសកល ចូលឆ្នាំប្រពៃណីជាតិខ្មែរ បុណ្យភ្ជុំបិណ្ឌ និងពិធីបុណ្យជាតិផ្សេងៗទៀត ។

## ៥. ទីកន្លែងកាលបរិច្ឆេទនៃការទទួលពាក្យ និងឈប់ទទួលពាក្យ

- **កាលបរិច្ឆេទចាប់ផ្ដើម និងឈប់ទទួលពាក្យ**
  - ចាប់ផ្ដើមទទួលពាក្យ ៖ ថ្ងៃទី២២ ខែមេសា ឆ្នាំ២០២៤ រៀងរាល់ម៉ោងធ្វើការ (០៨:០០ ដល់ ១៦:៣០)
  - ឈប់ទទួលពាក្យ ៖ ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២៤ វេលាម៉ោង ១៦:៣០ ។

- **ទីកន្លែងទទួលពាក្យ និងទំនាក់ទំនងព័ត៌មាន**

  នាយកដ្ឋាន រដ្ឋបាល-ធនធានមនុស្ស នៃកំពង់ផែស្វយ័តក្រុងព្រះសីហនុ
  ជាន់ទី ១ នៃអគាររដ្ឋបាល កំពង់ផែស្វយ័តក្រុងព្រះសីហនុ
  តិរវិថី សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន, សង្កាត់លេខ ៣, ក្រុង- ខេត្តព្រះសីហនុ
  **លេខទូរស័ព្ទ និងតេឡេក្រាម** ( Telegram )
  ទូរស័ព្ទ: (៨៥៥) ១០ ៧៨៨ ៨៨០ / ៩៥ ៦៦៨ ៨៩៧ / ១១ ៨១៧ ៨៤៧ ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជនទាំងអស់ មេត្តាជ្រាបជាព័ត៌មាន ។

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា**
**ទទួលបន្ទុកជាប្រធានអគ្គនាយក**

PORT AUTONOME DE SIHANOUKVILLE

**លូ គឹមឈន់**

**ចម្លងជូន៖**
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- និយ័តករមូលបត្រកម្ពុជា
- ក្រុមប្រឹក្សាភិបាល កសស

  **"ដើម្បីជូនជ្រាប"**
- ផ្សារមូលបត្រកម្ពុជា និង ក្រុមហ៊ុនមូលបត្រ

  **"ដើម្បីជូនផ្សព្វផ្សាយ"**
- ឯកសារ-កាលប្បវត្តិ



តិរវិថី សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ
Tarak Vithei Samdech Akka Moha Sena Padei Techo HUN SEN
Sangkat Nº 3, Preah Sihanouk City, Preah Sihanouk Province
Office : 034 933 416; 034 933 511 Pilot : 034 933 507; Fax: 034 933 693
E-mail: pasinfo@pas.gov.kh; spsez@pas.gov.kh
Website: www.pas.gov.kh